**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៩២១ ព.ណ.កសប

ថ្ងៃ សុក្រ ១ រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០២២

**<u>ជម្រាបមក</u>**

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន ជេធី អ៊ិនធើណេសិនណាល (ខេមបូឌា) ឯ.ក**

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលថ្នាំជក់ និងបារីម៉ាក "**MEVIUS**", "**WINSTON**" និង "**CAMEL**" ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ជេធី អ៊ិនធើណេសិនណាល (ខេមបូឌា) ឯ.ក**។

**យោង:** - មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ជេធី អ៊ិនធើណេសិនណាល (ខេមបូឌា) ឯ.ក** ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០២២
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខលេខ ១៨៨៦ ព.ណ កសប ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០២០
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Japan Tobacco Inc. ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣៩៤៥៦/១១ ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០២១
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៥៩៦/៩២ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៥៧៩/៩២ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលថ្នាំជក់ និងបារីពាក់ម៉ាកខាងលើ ក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុន **ជេធី អ៊ិនធើណេសិនណាល (ខេមបូឌា) ឯ.ក** ដែលទទួលបានពីក្រុមហ៊ុន Japan Tobacco Inc. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាកដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតបន្តសុពលភាពកត់ត្រានេះ មានសុពលភាពរយៈ ២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០២២ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Japan Tobacco Inc. ដែលជាម្ចាស់ម៉ាក ។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

***<u>ចម្លងជូន:</u>***
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469